ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខ : ...........✓..........................

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សា និងសម្រេចលើរបាយការណ៍ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃអង្គារ ១៣រោច ខែមាឃ នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ម៉ោង ៩ព្រឹក នៅសាលប្រជុំអគារ ១ ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបើកកិច្ចប្រជុំពិភាក្សា ពិនិត្យ និង សម្រេចទៅលើរបាយការណ៍ឆ្នាំ២០១៧ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ (គ.ជ.ប.ជ)តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។ សមាសភាពចូលរួមកិច្ចប្រជុំនេះមាន ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករង អគ្គលេខាធិការរង មេបញ្ជាការរងកងរាជអាវុធហត្ថផ្ទៃប្រទេស មេបញ្ជាការរងព្រំដែន ប្រធាន-អនុប្រធាននាយកដ្ឋាន និងមន្ត្រីតំណាង ដែលមានចំនួនសរុប ៥៧នាក់ (ស្រី ១៩នាក់) ជាតំណាងមកពីក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងព័ត៌មាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីចាត់ការព្រំដែន កងរាជអាវុធហត្ថផ្ទៃប្រទេស ក្រសួងមុខងារសាធារណៈ ក្រសួងធម្មការ និងសាសនា ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ និងក្រសួងការបរទេស ។

គោលបំណងនៃកិច្ចប្រជុំគឺ ដើម្បីពិភាក្សាពិនិត្យ កែសម្រួល និងបញ្ចូលបន្ថែមនូវចំណុចខ្វះខាតលើរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧ ។ កិច្ចប្រជុំបានប្រព្រឹត្តទៅដោយមានការចូលរួមយោបល់យ៉ាងយកចិត្តទុកដាក់ ដោយតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ធ្វើការកែសម្រួល និងបំពេញបន្ថែមនូវចំណុចខ្វះខាតរបស់ខ្លួនមួយចំនួន និងជាទីបញ្ចប់នៃការត្រួតពិនិត្យ និងផ្លាស់ប្តូរយោបល់ទៅវិញទៅមករួចមក លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន មានប្រសាសន៍ណែនាំការងារសម្រាប់ពេលត្រឡប់ទៅវិញគឺ ត្រូវពិនិត្យឡើងវិញម្តងទៀត និងស្វែងរកទិន្នន័យសម្រាប់ ចំណុចខ្វះខាត ដោយទុករយៈពេល១សប្តាហ៍ សម្រាប់ការឆ្លើយតប និងបញ្ជូនមកអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់មួយព្រឹក ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ អង្គារ ១៣រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ពស២៥៦១.
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៨
**អ្នកធ្វើកំណត់ហេតុ**

ព.ត្រី ចន្ទ បញ្ញា